# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៧៤០ សហវ.ប្រក

អង្គភាពប្រឆាំងអំពើពុករលួយ
ចូល លេខ ១១១៣ / ២០២១
ថ្ងៃទី ២៣.១១.២១ ម៉ោង ១០:៤០

## ប្រកាសអន្តរក្រសួង
## ស្តីពី
## ការបង្កើតមូលនិធិវិនិយោគទ្រទ្រង់កិច្ចអភិវឌ្ឍន៍សហគមន៍មូលដ្ឋាន

### ឧបនាយករដ្ឋមន្ត្រី
### រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៧ ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែនិងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០១/០៩ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានរ៉ែ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៨ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្ម មាត្រា៣ មាត្រា២៣ មាត្រា៣០ មាត្រា៣៣ មាត្រា៣៤ មាត្រា៣៥ មាត្រា៣៦ មាត្រា៣៧ មាត្រា៣៨ មាត្រា៣៩ និងមាត្រា៤០ នៃច្បាប់ស្តីពីការគ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានរ៉ែ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666

- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៧ អនក្រ.បក ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែ និងថាមពល
- បានឃើញអនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រងអាជ្ញាបណ្ណស្វែងរុករក និងអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ
- បានឃើញប្រកាសអន្តរក្រសួងលេខ ៧៦០ សហវ.ប្រក ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២០ ស្តីពីអត្រាសួយសារលើតម្លៃផលិតផលរ៉ែ និងនីតិវិធីនៃការបង់ថ្លៃសួយសារ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរ៉ែនិងថាមពលនិងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១.-**

ត្រូវបានអនុញ្ញាតឱ្យបង្កើតមូលនិធិរ៉ែទ្រទ្រង់កិច្ចអភិវឌ្ឍន៍សហគមន៍មូលដ្ឋាន (ហៅកាត់ថា "មូលនិធិរ៉ែ") ក្រោមការគ្រប់គ្រង និងចាត់ចែង ដោយរដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល។

សម្បទានិកដែលបានទទួលអាជ្ញាបណ្ណធនធានរ៉ែ ឬលិខិតអនុញ្ញាតពីក្រសួងរ៉ែនិងថាមពលនៅក្នុងការធ្វើអាជីវកម្មធនធានរ៉ែទាំងអស់ លើកលែងតែសម្បទានិកដែលបានទទួលអាជ្ញាបណ្ណស្វែងរុករក អាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែលោហៈ និងអាជ្ញាបណ្ណកែច្នៃធនធានរ៉ែ (ហៅកាត់ថា "សម្បទានិក") ត្រូវបង់ជូនរដ្ឋនូវប្រាក់មូលនិធិរ៉ែទ្រទ្រង់កិច្ចអភិវឌ្ឍន៍សហគមន៍មូលដ្ឋាន ដោយផ្អែកលើបរិមាណផលិតផលរ៉ែដែលទាញយកបាន ស្របតាមការកំណត់ក្នុងប្រការ២ នៃប្រកាសនេះ។

ចំពោះសម្បទានិកដែលបានទទួលអាជ្ញាបណ្ណស្វែងរុករក ឬអាជ្ញាបណ្ណកែច្នៃធនធានរ៉ែ ត្រូវបង់ជូនរដ្ឋនូវប្រាក់មូលនិធិរ៉ែទ្រទ្រង់កិច្ចអភិវឌ្ឍន៍សហគមន៍មូលដ្ឋានតាមគោលការណ៍ស្ម័គ្រចិត្ត។

ចំពោះសម្បទានិកដែលបានទទួលអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែលោហៈ ត្រូវបង់ជូនរដ្ឋនូវប្រាក់មូលនិធិរ៉ែទ្រទ្រង់កិច្ចអភិវឌ្ឍន៍សហគមន៍មូលដ្ឋានតាមការចរចា។

ប្រការ២.-

ប្រាក់មូលនិធិរ៉ែត្រូវបានកំណត់ដូចខាងក្រោម÷

ក./ ផលិតផលរ៉ែសំណង់ (គិតលើបរិមាណផលិតនៅអណ្ដូងរ៉ែ)

| ល.រ | ផលិតផលរ៉ែ | មូលនិធិរ៉ែ |
|---|---|---|
| ១ | ថ្មបំបែកគ្រប់ប្រភេទ | ០,២០ ដុល្លារអាមេរិក ក្នុងមួយម៉ែត្រគីុគុណ |
| ២ | ក្រួសក្រាវែល | ០,២០ ដុល្លារអាមេរិក ក្នុងមួយម៉ែត្រគីុគុណ |
| ៣ | ខ្សាច់(ទន្លេ, ស្ទឹង, បឹង, ព្រែក, អូរ, សមុទ្រ) ខ្សាច់បក(ខ្សាច់សំណង់) និងដីល្បាយខ្សាច់ | ០,០៥ ដុល្លារអាមេរិក ក្នុងមួយម៉ែត្រគីុគុណ |
| ៤ | ដីក្រហម(ឡាតេរីត) និងខ្សាច់ភ្នំ | ០,០៥ ដុល្លារអាមេរិក ក្នុងមួយម៉ែត្រគីុគុណ |
| ៥ | ដីល្បាប់ ដីល្បាយដីឥដ្ឋ ដីឥដ្ឋ និងអាចម៍ដី | ០,០៥ ដុល្លារអាមេរិក ក្នុងមួយម៉ែត្រគីុគុណ |
| ៦ | ខ្សាច់សំណង់ និងដីល្បាយខ្សាច់ ក្នុងគោលបំណងនាំចេញ | ០,១០ ដុល្លារអាមេរិក ក្នុងមួយម៉ែត្រគីុគុណ |
| ៧ | ឡាតេរីតអារ | ០,៦៥ ដុល្លារអាមេរិក ក្នុងមួយម៉ែត្រគីុគុណ |
| ៨ | ថ្មអារ(ប្លុក ឬ សន្លឹក) | ១ ដុល្លារអាមេរិក ក្នុងមួយម៉ែត្រគីុគុណ |
| ៩ | ថ្មអារ(ប្លុក) ក្នុងគោលបំណងនាំចេញ | ១ ដុល្លារអាមេរិក ក្នុងមួយម៉ែត្រគីុគុណ |
| ១០ | ប៉ាហ្គោឌីត(ថ្មកែវ) | ១ ដុល្លារអាមេរិក ក្នុងមួយតោន |

ខ./ ផលិតផលរ៉ែឧស្សាហកម្ម

| ល.រ | ផលិតផលរ៉ែ | មូលនិធិរ៉ែ |
|---|---|---|
| ១ | ត្បូងថ្ម | ០,១០ ដុល្លារអាមេរិក ក្នុងមួយតោន |
| ២ | ដីឥដ្ឋ កុល្លាភាជន៍ | ០,០៥ ដុល្លារអាមេរិក ក្នុងមួយម៉ែត្រគីុគុណ |
| ៣ | ថ្មកំបោរ និងដូឡូមីត (ប្រើប្រាស់ក្នុងវិស័យ កសិកម្ម ឧស្សាហកម្ម) | - ១ ៥០០ ដុល្លារអាមេរិក ក្នុងមួយឆ្នាំ សម្រាប់ផលិតកម្មប្រចាំឆ្នាំទាបជាង ឬស្មើ ៣០ ០០០ តោន<br>- ០,០៥ ដុល្លារអាមេរិក ក្នុងមួយតោន សម្រាប់ផលិតកម្មប្រចាំឆ្នាំលើសពី ៣០ ០០០ តោន |
| ៤ | ថ្មកំបោរ(ប្រើប្រាស់ក្នុងវិស័យ-លោហស្សាហកម្ម) | ០,០៥ ដុល្លារអាមេរិក ក្នុងមួយតោន |

| | | |
|---|---|---|
| ៥ | ផ្លូស្វាត | ០,១០ ដុល្លារអាមេរិក ក្នុងមួយតោន |
| ៦ | ខ្សាច់ស៊ីលីស | ០,១០ ដុល្លារអាមេរិក ក្នុងមួយតោន |
| ៧ | ខ្សាច់ស៊ីលីស ក្នុងគោលបំណងនាំចេញ | ០,២០ ដុល្លារអាមេរិក ក្នុងមួយតោន |
| ៨ | ទឹកក្ដៅក្រោមដី និងទឹកខនិជ | ០,០២ ដុល្លារអាមេរិក ក្នុងមួយម៉ែត្រគូប |
| ៩ | បុកស៊ីត សម្រាប់ ឧស្សាហកម្មក្នុងស្រុក ឬនាំចេញ | ០,១០ ដុល្លារអាមេរិក ក្នុងមួយតោន លើបរិមាណបុកស៊ីតដែលលាងរួច |

**គ./ ត្បូងថ្មមានតម្លៃ ពាក់កណ្ដាលមានតម្លៃ និងគុណភាពប្រហាក់ប្រហែល**

| ល.រ | ផលិតផលរ៉ែ | មូលនិធិរ៉ែ |
|---|---|---|
| ១ | ត្បូងថ្មមានតម្លៃ ពាក់កណ្ដាលមានតម្លៃ និងគុណភាពប្រហាក់ប្រហែល (ចំពោះប្រភេទឧស្សាហកម្ម) | - ១០ ០០០ ដុល្លារអាមេរិក ក្នុងមួយឆ្នាំ ចំពោះសមត្ថភាពម៉ាស៊ីនផលិតកម្មតិចជាង ឬស្មើ ៥០ ម៉ែត្រគូប<br>- ២០ ០០០ ដុល្លារអាមេរិក ក្នុងមួយឆ្នាំ ចំពោះសមត្ថភាពម៉ាស៊ីនផលិតកម្មលើសពី ៥០ ម៉ែត្រគូប |
| ២ | ត្បូងថ្មមានតម្លៃ ពាក់កណ្ដាលមានតម្លៃ និងគុណភាពប្រហាក់ប្រហែល (ចំពោះការប្រកបអាជីវកម្មជាលក្ខណៈគ្រួសាររបស់ប្រជាពលរដ្ឋខ្មែរ) | មិនយក |

**ឃ./ ផលិតផលរ៉ែលោហៈ**

| ល.រ | ផលិតផលរ៉ែ | មូលនិធិរ៉ែ |
|---|---|---|
| ១ | ផលិតផលរ៉ែលោហៈ រួមទាំងលោហៈមានតម្លៃ លោហៈមូលដ្ឋាន លោហៈកម្រ និងប្រភេទប្រហាក់ប្រហែល | តាមការចរចា |

**ប្រការ៣.-**

សម្បទានិកត្រូវបង់មូលនិធិរ៉ែប្រចាំត្រីមាសនីមួយៗ ស្របពេលជាមួយគ្នានឹងការបង់សួយសារលើតម្លៃផលិតផលរ៉ែ។

ការដាក់ប្រកាស ការបង់ប្រាក់រំដោះមូលនិធិរ៉ែ និងការទូទាត់ប្រាក់រំដោះមូលនិធិរ៉ែប្រចាំត្រីមាស ត្រូវអនុវត្តតាមនីតិវិធី នៃការដាក់ប្រកាស ការបង់សួយសារ ដូចមានចែងក្នុងប្រកាសអន្តរក្រសួង ស្ដីពីអត្រាសួយសារលើតម្លៃផលិតផលរ៉ែនិងនីតិវិធីនៃការបង់ថ្លៃសួយសារ។

**ប្រការ៤.-**

នីតិវិធីនៃការគ្រប់គ្រង ការចាត់ចែង និងការកត់ត្រាមូលនិធិរ៉ែ÷

ក-ការប្រមូលនិងការកត់ត្រាមូលនិធិរ៉ែ÷

- មូលនិធិរ៉ែ ចំនួន ១០០% (មួយរយភាគរយ) ត្រូវបង់ចូលគណនី របស់ក្រសួងរ៉ែនិងថាមពល នៅធនាគារពាណិជ្ជដៃគូ
- មូលនិធិរ៉ែត្រូវបង់ក្នុងពេលជាមួយនឹងការបង់សួយសារ ដោយត្រូវអនុវត្តតាមបែបបទ និងនីតិវិធីដូចមានកំណត់ក្នុងប្រការ៣នៃប្រកាសនេះ។

ខ-គោលដៅប្រើប្រាស់មូលនិធិរ៉ែ÷

មូលនិធិរ៉ែនេះត្រូវបានបង្កើតឡើង ដើម្បីបង្កើនសុខដុមនីយកម្មរវាងសហគមន៍មូលដ្ឋានជាមួយនឹងការដ្ឋានរ៉ែ ដោយចូលរួមកាត់បន្ថយផលប៉ះពាល់បរិស្ថាននិងសង្គម ផ្តល់ប្រយោជន៍ដោយផ្ទាល់ និងដោយប្រយោលដល់សហគមន៍មូលដ្ឋានដែលមានប្រតិបត្តិការរ៉ែ។

មូលនិធិរ៉ែត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់សម្រាប់÷

ខ.១-អភិវឌ្ឍមូលដ្ឋានឃុំ-សង្កាត់ ដែលរងផលប៉ះពាល់ផ្ទាល់ ឬប្រយោល ដោយសារប្រតិបត្តិការរ៉ែ

ខ.២-ដោះស្រាយផលប៉ះពាល់ ដោយសារប្រតិបត្តិការរ៉ែ បន្ថែមពីលើការដោះស្រាយដោយសម្បទានិកសាមី ក្នុងករណីចាំបាច់។

គ-ការគ្រប់គ្រងនិងចាត់ចែងមូលនិធិរ៉ែត្រូវកំណត់ដោយគោលការណ៍និងនីតិវិធីនៃការប្រើប្រាស់មូលនិធិរ៉ែទ្រទ្រង់កិច្ចអភិវឌ្ឍន៍សហគមន៍មូលដ្ឋាន របស់ក្រសួងរ៉ែនិងថាមពល ស្របតាមនីតិវិធីហិរញ្ញវត្ថុសាធារណៈ។

**ប្រការ៥.-**

ក-កាតព្វកិច្ចហិរញ្ញវត្ថុពាក់ព័ន្ធនឹងមូលនិធិរ៉ែ ដែលមានចែងក្នុងកិច្ចព្រមព្រៀង ឬឯកសារផ្សេងៗកន្លងមក ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះត្រូវទុកជានិរាករណ៍ លើកលែងតែករណីកិច្ចព្រមព្រៀងទ្វេភាគី ឬពហុភាគី ដែលទទួលបានគោលការណ៍ឯកភាពពីរាជរដ្ឋាភិបាល ឬកាតព្វកិច្ចហិរញ្ញវត្ថុនោះជាបដិភាគរបស់រាជរដ្ឋាភិបាល ឬត្រូវបានដាក់ជាបន្ទុករបស់រដ្ឋ។

ខ-ទោះបីទទួលបានការអនុញ្ញាតលើកលែងការបង់មូលនិធិរ៉ែ ដូចមានចែងក្នុងចំណុច (ក) ខាងលើក៏ដោយ ក៏សម្បទានិកនៅតែមានកាតព្វកិច្ចក្នុងការប្រកាស តាមការកំណត់ក្នុងប្រការ៣ នៃប្រកាសនេះដដែល។

**ប្រការ៦.-**

ក្រសួងរ៉ែនិងថាមពលត្រូវធ្វើរបាយការណ៍អំពីលទ្ធផលនៃការអនុវត្តមូលនិធិរ៉ែប្រចាំត្រីមាស ជូនមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ) ដោយភ្ជាប់មកជាមួយនូវឯកសារបង់ចំណូលទាំងអស់ និងរបាយការណ៍គណនីមូលនិធិរ៉ែ (Bank Statement)។

មន្ទីររ៉ែនិងថាមពលត្រូវធ្វើរបាយការណ៍អំពីលទ្ធផលអនុវត្តមូលនិធិរ៉ែប្រចាំត្រីមាស ជូនមកក្រសួងរ៉ែនិងថាមពល និងចម្លងជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ) ដោយភ្ជាប់មកជាមួយនូវឯកសារបង់ចំណូលទាំងអស់។

**ប្រការ៧.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសអន្តរក្រសួងនេះត្រូវទុកជានិរាករណ៍។

**ប្រការ៨.-**

អង្គភាពពាក់ព័ន្ធក្រោមចំណុះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងរ៉ែនិងថាមពល ព្រមទាំងសម្បទានិកដូចមានក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះឱ្យមានប្រសិទ្ធភាព។

**ប្រការ៩.-**

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្ត ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២២តទៅ។

ថ្ងៃសុក្រ ១កើត ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៥ ខែវិច្ឆិកា ឆ្នាំ២០២១

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រី**

**ក្រសួងរ៉ែនិងថាមពល**

**ស៊ុយ សែម**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័ន
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- អង្គភាពប្រឆាំងអំពើពុករលួយ
- រដ្ឋបាលរាជធានី-ខេត្ត
- ដូចប្រការ ៨ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ